មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា
Cambodia Development Center

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ញត្តិគាំទ្រ
## ចំពោះការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០

មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា (ម.អ.ក) បានពិនិត្យ និងតាមដានយ៉ាងដោយយកចិត្តទុកដាក់នូវដំណើរការនៃការធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ និងច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានាដំណើរប្រព្រឹត្តទៅជាប្រក្រតីភាពនៃស្ថាប័នជាតិ ដែលរួមមាន ដំណាក់កាលផ្តួចផ្តើម ការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាធម្មនុញ្ញ ការឆ្លងសេចក្តីព្រាងច្បាប់នៅតាមនីតិវិធីនិមួយៗ ព្រមទាំងការធ្វើសន្និសីទសារព័ត៌មានរបស់ក្រសួងយុត្តិធម៌ កាលពីថ្ងៃទី១៤ ខែកក្កដា កន្លងទៅ ដើម្បីធ្វើការពន្យល់សាធារណជន ប្រកបដោយតម្លាភាព។

ផ្អែកលើមូលដ្ឋាននេះ ក្នុងនាមជាស្ថាប័នស្រាវជ្រាវដែលប្រកាន់ខ្ជាប់វិជ្ជាជីវៈ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជាបានយល់ឃើញថា ខ្លឹមសារ និងដំណើរការរៀបចំវិសោធនកម្មរដ្ឋធម្មនុញ្ញនេះ បានប្រព្រឹត្តិទៅប្រកបដោយភាពត្រឹមត្រូវ សមស្របតាមកាលៈទេសៈ និងបរិបទនៃដំណើរវិវឌ្ឍរបស់សង្គម ដោយអនុលោមតាមគោលការណ៍គ្រឹះនៃនីតិរដ្ឋ និងសណ្តាប់ធ្នាប់គតិយុត្តដែលបានចាក់ឬសយ៉ាងមាំក្នុងសង្គមកម្ពុជា។ វិសោធនកម្មនេះមានគោលបំណងចម្បងបម្រើឱ្យឧត្តមប្រយោជន៍ជាតិ ធានាបាននូវគោលការណ៍គ្រឹះនៃរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញ និងរបបសភានិយម ព្រមទាំងការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ធានាបាននូវសុខសន្តិភាព សណ្តាប់ធ្នាប់សាធារណៈ និងស្ថិរភាពនយោបាយរបស់ប្រទេសជាតិ។

ក្នុងន័យនេះ មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា សូមប្រកាសជាឱឡារិកគាំទ្រយ៉ាងពេញទំហឹងចំពោះវិសោធនកម្មរដ្ឋធម្មនុញ្ញលើកទី១០ លើមាត្រា១៩ថ្មី(មួយ) មាត្រា៨៩ មាត្រា៩៨ថ្មី មាត្រា១០២ថ្មី មាត្រា១១៩ថ្មី(មួយ) និងមាត្រា១២៥ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ថ្មី និងមាត្រា៤ថ្មី នៃច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការប្រព្រឹត្តទៅជាប្រក្រតីនៃស្ថាប័នជាតិ។

ជាថ្មីម្តងទៀត មជ្ឈមណ្ឌលអភិវឌ្ឍន៍កម្ពុជា សូមសម្តែងនូវមោទកភាព មនោសញ្ចេតនាស្នេហាជាតិ និងប្តេជ្ញាបន្តគោរពរដ្ឋធម្មនុញ្ញ និងនីតិរដ្ឋដើម្បីការពារឧត្តមប្រយោជន៍ជាតិ រក្សាសុខសន្តិភាព និងការអភិវឌ្ឍ សំដៅសម្រេចបានចក្ខុវិស័យសំខាន់ៗ ជាពិសេសធ្វើឱ្យព្រះរាជាណាចក្រកម្ពុជាជាប្រទេសអភិវឌ្ឍនាឆ្នាំ២០៥០។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០២២


+855 (0) 10 950 456 info@cd-center.org www.cd-center.org